Australian Government
Department of Social Services

# អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ

DSS1849.02.16

មនុស្សគ្រប់រូបចង់បានក្រុមគ្រួសាររបស់ខ្លួនសប្បាយរីករាយ មានសុខភាពល្អ ហើយមានសុវត្ថិភាព។



យើងរាល់គ្នាមានសិទ្ធិដើម្បីរួចផុតពីអំពើហិង្សាក្នុងលំនៅដ្ឋានរបស់យើង និងក្នុងសហគមន៍របស់យើង។



ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នានៅក្នុងប្រទេសអូស្ត្រាលី។




អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានខាងផ្លូវភេទ និងអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបទឧក្រិដ្ឋនៅក្នុងប្រទេសអូស្ត្រាលី ទោះបីជាកើតឡើងនៅក្នុងផ្ទះក៏ដោយ។ អំពើហិង្សាក្នុងគ្រួសារមិនត្រឹមគ្រាន់តែការវាយតប់នោះទេ។ វាអាចមានន័យទៅលើការស្រែកដាក់ដោយបង្ខំ ការបៀតបៀនយាយីដល់កុមារ ការគ្រប់គ្រងប្រាក់កាសរបស់ក្រុមគ្រួសារ ឬការបញ្ឈប់ដៃគូមិនឲ្យជួបមិត្តភក្តិ និងក្រុមគ្រួសារ។



ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។ ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នក ស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ជាបន្ទាន់ **សូមនិយាយទៅកាន់ប៉ូលីស ឬទូរស័ព្ទទៅប៉ូលីសលេខ 000។**




មានសេវាយល់ដឹងពីវប្បធម៌នៅក្នុងប្រទេសអូស្ត្រាលី ដែលអាចជួយធ្វើឲ្យអ្នកមានសុវត្ថិភាព ហើយសប្បាយរីករាយ។




អ្នកអាចទទួលបានជំនួយជាមួយនឹង៖

- អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ
- ការរំលោភបំពានខាងផ្លូវភេទ
- អាពាហ៍ពិពាហ៍ដោយបង្ខំ
- ការធ្វើបាបកុមារ
- ការរំលោភបំពានខាងពាក្យសម្ដី




ទូរស័ព្ទប៉ូលីសលេខ 000 ប្រសិនបើអ្នកស្ថិតនៅក្នុងសភាពគ្រោះថ្នាក់។

ទូរស័ព្ទ 1800 RESPECT ដោយឥតគិតថ្លៃលេខ 1800 737 732
ប្រសិនបើអ្នកត្រូវការការប្រឹក្សាយោបល់ និងព័ត៌មានរក្សាជាសម្ងាត់។
ឬបើកចូលវិបសាយនៅត្រង់ www.1800RESPECT.org.au។

ទូរស័ព្ទប៉ូលីសសហព័ន្ធអូស្ត្រាលី (Australian Federal Police) លេខ 131 237
ប្រសិនបើអ្នកកំពុងប្រឈមមុខនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ។

ទូរស័ព្ទ សេវាបកប្រែភាសាសរសេរ និងនិយាយ (Translating and Interpreting Service) ដោយឥតគិតថ្លៃលេខ 131 450 ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា។

(C) CALDWorld M: 0419525119